# អ្នកឃ្លាំមើលថា ការកែទម្រង់ស្ថាប័នរដ្ឋគួរជាជម្រើសសម្រាប់ទីលានប្រកួតការបោះឆ្នោតឆ្នាំ ២០២៣។




អ្នកឃ្លាំមើលមួយចំនួនយល់ឃើញថា ទីលានប្រកួតការបោះឆ្នោតអាណត្តិថ្មីនេះ អ្នកនយោបាយគួរប្រកួតគ្នាដោយផ្តោតលើការធ្វើកំណែទម្រង់ស្ថាប័នរដ្ឋ ដើម្បី

ការពារផលប្រយោជន៍ជាតិ ជាជាងប្រើប្រាស់ធនធានជាតិ និងប្រព័ន្ធច្បាប់យកប្រៀបលើដៃគូប្រកួត ផ្ទុយពីគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលជាដើមចមជំរុញឱ្យកម្ពុជាបន្តជាប់ផុងក្នុងវិបត្តិជាតិ។

ការបារម្ភនេះកើតឡើងក្រោយពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានជាថ្មីទៀតពីជម្រើសប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីឆ្លើយតបទៅនឹងការរិះគន់ពីគណបក្សភ្លើងទៀន មុនការបោះឆ្នោតជាតិឆ្នាំ២០២៣ ដែលកាន់តែខិតជិតមកដល់។

ការគំរាមរបស់មេដឹកនាំបក្សកាន់អំណាចនេះ ក្រោយពីគណបក្សភ្លើងទៀនចេញសេចក្តីថ្លែងការណ៍ចាត់ទុកវិធានការលើមេដឹកនាំរបស់ខ្លួនមួយចំនួន ដូចជា ករណីចាប់ឃុំខ្លួនលោក **ថាច់ សេដ្ឋា** អនុប្រធានគណបក្សថ្មីៗនេះ រួមទាំងចំណាត់ច្បាប់ទៅលើមន្ត្រីជាន់ខ្ពស់គណបក្សភ្លើងទៀន លោក **សុន ឆ័យ** និង លោក **គង់ គាំ** ជាដើមនោះ ថាជាការប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីគំរាមកំហែងនិងគាបសង្កត់ទៅលើគណបក្សភ្លើងទៀន។

សារឆ្លើយឆ្លងនេះធ្វើឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រតិកម្មជាថ្មីទៀត ក្នុងពិធីមួយកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣នេះ។

លោកថា៖ «**រឿងស្អីសុទ្ធតែរឿងនយោបាយ រឿងហ្នឹងនិយាយគ្នាឱ្យច្បាស់។ អត់ទេ! គណបក្សប្រជាជន មិនអាចទុកឱ្យអ្នកឯងធ្វើរបៀបហ្នឹងតទៅទៀតទេ យើងប្តឹងទៀត! បើមិនឱ្យប្តឹង មានស្អី អញលើកបាតុកម្ម ដាក់ឯងរត់ពេញទឹកពេញដី រកកន្លែងរត់មិនឃើញទៀតណោះ។ នេះចេះគេថ្នមហើយប៉ុណ្ណឹងនោះ ចេញមកវាឈ្លើយតែម្តង**»។

ភ្លាមៗក្រោយពីការថ្លែងសាររបស់នាយករដ្ឋមន្ត្រីនេះ គណបក្សប្រជាជនកម្ពុជា ក៏ដូចជាស្ថាប័នរដ្ឋមួយចំនួនបានចេញសេចក្តីថ្លែងការណ៍គាំទ្រចំណាត់ការរបស់រដ្ឋាភិបាល លើវិធានការដាក់ទោសទណ្ឌបុគ្គលតាមការកំណត់នៃច្បាប់។

សេចក្ដីថ្លែងការណ៍គណបក្សប្រជាជនកម្ពុជា បានគូសបញ្ជាក់ថា៖ «**គណបក្សប្រជាជនកម្ពុជា ពុំអាចទទួលយកបានដាច់ខាតនូវការប្រមាថកាតទាន និងការចោទប្រកាន់ទាំងបំពានរបស់គណបក្សភ្លើងទៀន។ គណបក្សប្រជាជនកម្ពុជា នឹងធ្វើអ្វីៗទាំងអស់តាមច្បាប់ ដើម្បីការពារខ្លួន មិនឱ្យគេរំលោភបំពានបានឡើយ**»។

ជុំវិញបញ្ហានេះ នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោកស្រី **ចក់ សុភាព** កត់សម្គាល់ឃើញថា ទីលានប្រកួតនយោបាយនៅកម្ពុជា ឱ្យតែជិតដល់រដូវកាលបោះឆ្នោតមកដល់ អ្នកនយោបាយតែងតែហែកហួរគ្នាលើសង្វៀននយោបាយ។ ប៉ុន្តែលោកស្រីថា បញ្ហានេះ វាសមល្មមដែលអ្នកនយោបាយដល់ពេលបញ្ឈប់នូវវប្បធម៌ហែកហួរគ្នា ហើយងាកមកប្រកួតគោលនយោបាយដែលមានប្រយោជន៍សម្រាប់ពលរដ្ឋ និងប្រទេសជាតិ។

ក្នុងន័យនេះ លោកស្រីគូសបញ្ជាក់ថា អ្នកនយោបាយគួរតែជជែកគ្នា ពាក់ព័ន្ធនឹងការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ និងប្រព័ន្ធសុខាភិបាល ជាដើម ដើម្បីពង្រឹងគុណភាពសម្រាប់ជាប្រយោជន៍ជាតិ និងពលរដ្ឋ ជាជាងធ្វើញត្តិស្រែកបន្ទោសគ្នា វាយប្រហារគ្នាបែបបុគ្គលនោះ។

លោកស្រី **ចក់ សុភាព** យល់ថា តាមគោលការណ៍សិទ្ធិមនុស្ស អាជ្ញាធររដ្ឋ រួមទាំងមេដឹកនាំ ជាកម្មវត្ថុនៃការរិះគន់ មិនមែនប្រើច្បាប់ដើម្បីរឹតបន្តឹងសេរីភាពបញ្ចេញមតិ អំឡុងខ្លួនមានលទ្ធភាពប្រើប្រាស់ធនធានរដ្ឋទាំងនោះទេ។

លោកស្រីថា៖ «**សេចក្ដីណែនាំរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិហ្នឹង គេមិនលើកទឹកចិត្តឱ្យរដ្ឋ ឬក៏ថ្នាក់ដឹកនាំហ្នឹងប្រើប្រាស់ធនធាន ជាពិសេសធនធានរដ្ឋ ឬក៏ធនធានខ្លួនឯង ក៏ដោយសារខ្លួនឯងហ្នឹងមានអំណាចទៀតហ្នឹង ដើម្បីរឹតបន្តឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិទេ ព្រោះជាគោលការណ៍ គឺបុគ្គលសាធារណៈជាកម្មវត្ថុ**

នៃការរិះគន់។ អ៊ីចឹងកន្លែងនេះជាចំណុចមួយដែលយើងមើលអំពីជ្រុងនៃគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលគេណែនាំអ៊ីចឹង»។

លោកស្រីយល់ថា បើវប្បធម៌វាយប្រហារបែបបុគ្គលមិនត្រូវបានកែលម្អ នោះនឹងបង្កភាពអ័ព្ទអួដល់បរិយាកាសបោះឆ្នោត ជំរុញឱ្យប៉ះពាល់ដល់មុខមាត់កម្ពុជាលើឆាកអន្តរជាតិ និងបន្សល់ទុកនូវបញ្ហាសង្គម។

នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា លោក **ប៉ិច ពិសី** លើកឡើងនៅថ្ងៃសុក្រនេះដែរថា ការរីកចម្រើនរបស់កម្ពុជាត្រូវផ្សាភ្ជាប់នឹងការវិវឌ្ឍនយោបាយទៅរកគន្លងប្រជាធិបតេយ្យ ធានាការបោះឆ្នោតមួយមានភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលការណ៍នេះទាមទារឱ្យមានការប្រកួតប្រជែងគ្នាមួយប្រកបដោយសុជីវធម៌ វិជ្ជាជីវៈខាងផ្នែកគោលនយោបាយ ចៀសវាងការវាយប្រហារ និងការប្រើប្រាស់វិធានការច្បាប់ ដើម្បីកៀបសង្កាត់ដៃគូប្រកួតដែលប្រើប្រាស់សិទ្ធិដើម្បីចូលរួមប្រកួតតាមស្មារតីរដ្ឋធម្មនុញ្ញ។

លោកថា៖ «ខ្ញុំជឿថា មកដល់ពេលនេះ ពលរដ្ឋចង់ឃើញការប្រកួតនយោបាយមួយដោយផ្តោតទៅលើគោលនយោបាយ ដោយផ្តោតទៅលើការតាំងចិត្តរបស់គណបក្សនយោបាយ ក្នុងការរុញនាវាកម្ពុជាឆ្ពោះទៅរកភាពជោគជ័យ ទាំងវិស័យសេដ្ឋកិច្ចទាំងវិស័យសង្គម ហើយនិងកិត្តិនាមរបស់កម្ពុជា ជាជាងការឈ្នះសង្វៀននយោបាយដោយការប្រើប្រាស់មធ្យោបាយដែលផ្ទុយពីគោលការណ៍ច្បាប់»។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក **ជិន ម៉ាលីន** ធ្លាប់លើកឡើងថា វិធានការច្បាប់តាមនីតិវិធីរបស់តុលាការ ជាវិធានតែមួយគត់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីឆ្លើយតបទៅនឹងសកម្មភាព និងបទល្មើសទាំងឡាយណាដែលច្បាប់ចាត់ទុកថាជាបទល្មើស មិនមែនជាការធ្វើទុក្ខបុកម្នេញការអនុវត្តសិទ្ធិទេ។

លោកថា៖ «ការឆ្លើយតបទៅនឹងសកម្មភាពដែលជាបទល្មើសហ្នឹង មិនមែនជាការរឹតត្បិតសិទ្ធិ ឬក៏ធ្វើទុក្ខបុកម្នេញពាក់ព័ន្ធទៅនឹងការអនុវត្តសិទ្ធិនោះទេ ក៏ប៉ុន្តែវាជាវិធានការតែមួយគត់នៅក្នុងសង្គមប្រជាធិបតេយ្យ នៅក្នុងការឆ្លើយតបទៅនឹងរាល់សកម្មភាពដែលច្បាប់ចាត់ទុកជាបទល្មើស»។

តែយ៉ាងណា លោកស្រី **ចក់ សុភាព** យល់ថា នៅស្រុកណាក៏គេយកប្រព័ន្ធច្បាប់ជាធំដែរ តែគេត្រូវមើលទៅលើគោលការណ៍ធំៗចំនួន២ ទើបអាចធានាយុត្តិធម៌សង្គមបាន ក្នុងនោះ ទី១ ត្រូវមើលថាតើច្បាប់នោះអនុលោមទៅតាមគោលការណ៍សិទ្ធិមនុស្សជាតិ និងអន្តរជាតិ ឬក៏អត់ រួមទាំងតាមដានពីប្រព័ន្ធនីតិរដ្ឋ និងទី២ ត្រូវមើលដែរថាតើការធ្វើច្បាប់ និងការធ្វើវិសោធនកម្មច្បាប់ ស្របទៅនឹងគោលការណ៍សិទ្ធិមនុស្សអន្តរជាតិឬក៏អត់។

បន្ថែមពីនេះ អ្នកឃ្លាំមើលពីតម្លាភាពសង្គម លោក **ប៊ិច ពិសី** មើលឃើញថា ក្នុងប្រទេសមួយ បើមានជម្លោះនយោបាយកើតឡើង នឹងធ្វើឱ្យមានការបែងចែកវណ្ណៈសង្គមកាន់តែខ្ពស់រវាងអ្នកមានអំណាច និងអ្នកទន់ខ្សោយ រវាងអ្នកមាននិងអ្នកក្រ ដែលធ្វើឱ្យសង្គមមានការបែកបាក់៕